SHH45108 (DC-Cam)

# ឃុន រ៉ុន៖ សាច់រឿងសង្ខេបអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងស្ថានភាពជំងឺបច្ចុប្បន្ន



### យុន រ៉ុនៈ អាយុ៥៥ឆ្នាំ រស់នៅភូមិបាក់នឹម ឃុំច្រេស ស្រុកជុំគិរី ខេត្តកំពត

ខ្ញុំឈ្មោះ យុន រ៉ុន អាយុ ៥៥ឆ្នាំ ខ្ញុំកើតនៅឆ្នាំ ១៩៧០។ បច្ចុប្បន្នខ្ញុំរស់នៅ ភូមិបាក់នឹម ឃុំច្រេស ស្រុកជុំគិរី ខេត្តកំពត។ ឪពុករបស់ខ្ញុំឈ្មោះ នួន យន (ស្លាប់) និងម្តាយឈ្មោះ ឡុង ណាន (ស្លាប់)។ ខ្ញុំមានបងប្អូន៧នាក់ នៅរស់រានមានជីវិតទាំងអស់។ ខ្សែជីវិតរបស់ខ្ញុំ នៅក្នុងរបបខ្មែរក្រហម ក្នុងអំឡុងពេលនោះ នៅពេលខ្មែរក្រហមបានចូលមកដល់ភូមិស្រុក ដែលខ្ញុំរស់នៅ និងបានជម្លៀសប្រជាជនចេញពីភូមិស្រុកទៅធ្វើការងារកន្លែងផ្សេងៗពីគ្នា។ ខ្ញុំត្រូវខ្មែរក្រហមបំបែកចេញពីគ្រួសារទៅធ្វើការនៅកងកុមារ។ ខ្មែរក្រហមបានប្រើខ្ញុំឱ្យកាប់ស្លឹកទន្រ្ទាងខែត្រ រើសអាចម៍គោ ទុកធ្វើជីដាក់ស្រែ។ ក្នុងរបបខ្មែរក្រហម ខ្ញុំឃើញមានខ្មែរក្រហមមួយក្រុមចាប់ប្រជាជនចងដៃ និងបានបណ្តើរជាជួរមកដល់ក្បែផ្ទះរបស់ខ្ញុំនិងបានចងជាមួយដើមឈើ មិនយូប៉ុន្មានក៏ខ្មែរក្រហមបានបណ្តើរទៅមុខបន្តទៀត ប៉ុន្តែខ្ញុំមិនដឹងថាក្រហមនាំប្រជាជនទាំងនោះទៅទីកន្លែងណាទេ។ បើនិយាយពីរបបអាហារវិញ ពេលខ្ញុំនៅធ្វើការជាកងកុមារ ខ្ញុំមិនមានអាហារហូបចុកគ្រប់គ្រាន់ទេ គឺមានត្រឹមតែបបរសពីរពេលក្នុងមួយថ្ងៃ ជួនកាលខ្មែរក្រហមដាំបាយស្លព្រលឹតទាំងសំបក។

ខ្ញុំបានធ្វើការងារជាកងកុមាររហូតដល់ឆ្នាំ ១៩៧៩ ពេលនោះ មានកងទ័ពវៀតណាមវាយចូលមកក្នុងទឹកដីកម្ពុជា សង្រ្គាមក៏បានកើតឡើង។ ដោយសារការភ័យខ្លាចនឹងសង្រ្គាមខ្ញុំបានភៀសខ្លួនទៅក្នុងព្រៃជាមួយឪពុកម្តាយ និងបងប្អូន ព្រមទាំងប្រជាជនផ្សេងៗទៀត។ ខ្ញុំរស់នៅលាក់ខ្លួនក្នុងព្រៃអស់ជាច្រើនខែ យប់កន្លែងណាដេកកន្លែងនោះ ដោយមិនមានអាហារហូបចុក។ អំឡុងពេល ខ្ញុំធ្វើដំណើរនៅក្នុងព្រៃបានប្រទះឃើញសាកសពមនុស្សស្លាប់ពាសពេញក្នុងព្រៃ អ្នកខ្លះស្លាប់ដោយគ្រាប់ស្លឹកឈើពីលើមិនបានទាំងកប់ផង។ ខ្ញុំប្រើជីវិតរស់នៅអស់ជាច្រើនខែ រហូតខ្ញុំទទួលដំណឹងថា សង្រ្គាមបានបញ្ចប់ ទើបខ្ញុំនិងក្រុមគ្រួសារនាំគ្នាវិលត្រឡប់រកភូមិស្រុកវិញ។

ខ្ញុំបានចូលរៀន បន្ទាប់ពីខ្មែរក្រហមដួលរលំ។ ខ្ញុំរៀនមិនបានយូប៉ុន្មាននោះទេ ក៏ត្រូវសម្រេចចិត្តឈប់រៀន ព្រោះជីវភាពក្រុមគ្រួសារក្រីក្រលំបាក ត្រូវនៅជួយឪពុកម្តាយធ្វើស្រែចម្ការដើម្បីចិញ្ចឹមប្អូនៗ។ អំឡុងឆ្នាំ ១៩៨២ ខ្ញុំត្រូវបានឪពុកម្តាយរៀបចំឱ្យខ្ញុំមានគ្រួសារ។ បន្ទាប់ពីខ្ញុំមានកូនពីនាក់ នៅក្នុងឆ្នាំ ១៩៩២ ខ្ញុំបានផ្លាស់ប្តូរមករស់នៅក្នុង ភូមិបាកនឹម ឃុំច្រេស ស្រុកជុំគិរី ខេត្តកំពត ហើយបានប្រកបមុខរបរជាកសិកររហូតដល់បច្ចុប្បន្ន។

បច្ចុប្បន្ននេះ ខ្ញុំមានជំងឺប្រចាំកាយដូចជា៖ ជំងឺសន្លាក់ដៃជើង ជំងឺហឺតរាំរ៉ៃ។ មូលហេតុដែលធ្វើឱ្យខ្ញុំកើតមានជំងឺទាំងនេះគឺបណ្ដាលមកពី កត្តាតំណរពូជពីគ្រួសារ ដោយសារតែលោកឪពុករបស់ខ្ញុំមានជំងឺហឺតពីមុនមក។ ចំពោះជំងឺសន្លាក់ដៃជើងវិញ គឺបណ្ដាលមកពីមូលហេតុ កាលពីនៅក្មេង ខ្ញុំពុំមានអាហារហូបចុកគ្រាប់គ្រាន់ និងបច្ចុប្បន្នខ្ញុំមានវ័យកាន់តែចាស់ជរា។ ចំពោះការព្យាបាលជំងឺរបស់ខ្ញុំវិញ ខ្ញុំបានទៅជួបគ្រូពេទ្យនៅតាមស្រុកភូមិ ដោយគ្រូពេទ្យបានផ្ដល់ជាថ្នាំលេបនិងថ្នាំចាក់ជូនរូបខ្ញុំសម្រាប់ប្រើប្រាស់។ ជាចុងក្រោយ ខ្ញុំសូមថ្លែងអំណរគុណដល់ក្រុមការនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានចុះមកសួរសុខទុក្ខដល់រូបខ្ញុំ និងសូមជូនពរឱ្យក្រុមការងារទាំងអស់ជួបសេចក្ដីសុខចំរើនជារៀងរហូត។